ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៨៨

ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១

**សាលដីកា**

លេខ ៣៨៦ VIII

ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋាន:ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤៥ “ក្រVI.គ.ធ” ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

- **បុគ្គលប្តឹងសាទុក្ខ គឺអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល**

- ជនជាប់ចោទឈ្មោះ [redacted] សុផាត ភេទប្រុស ឆ្នាំកំណើត១៩៨៦ សញ្ជាតិខ្មែរ កម្រិតវប្បធម៌ ថ្នាក់ទី០៦ មុខរបរ កម្មករបើកឡានដឹងសំណង់ ទីកន្លែងកំណើត និងទីលំនៅមុនពេ [redacted], ត្រពាំងថ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។ ឪពុកឈ្មោ [redacted] “រស់” ម្តាយឈ្មោ [redacted] “រស់” ពោះម៉ាយ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន ។



Scanned with CamScanner

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៦៧៩/២០ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល ។

ជាប់ចោទពីបទ **នាំយកចេញអនីតិជនជាអាទិ៍ដោយមិនស្របច្បាប់** និងបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២០, ២៣ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០៩ និងមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

មេធាវីការពារសិទ្ធិលោក [redacted] **ម៉ូរ៉ា** ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] សាវឿន ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិបឹងក្តុល ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ។ ជាម្តាយរបស់ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ១២ឆ្នាំ។

មេធាវីការពារសិទ្ធិលោក [redacted] **សុនី** លោកស្រី [redacted] **គន្ធី** លោក [redacted] **សំរួល** លោកស្រី [redacted] **ច័ន្ទលីដា** ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ឈ្មោះ [redacted] សុផាត បានទូរស័ព្ទប្រាប់ឱ្យជនរងគ្រោះឈ្មោះ [redacted] **ណារី** ភេទស្រី អាយុ១២ឆ្នាំ ឱ្យចេញពីផ្ទះនៅស្រុកពញាឮ ខេត្តកណ្តាល ដោយពុំមានការអនុញ្ញាតពីឪពុកម្តាយ ឱ្យមកណាត់ជួបគ្នានៅចំណុចផ្លូវ២០០៤ ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយសម្រាកចំនួន ០២យប់។ បន្ទាប់មកនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ឈ្មោះ [redacted] សុផាត ក៏បាននាំជនរងគ្រោះឈ្មោះ [redacted] **ណារី** បន្តស្នាក់នៅខេត្តព្រះសីហនុចំនួន ០២យប់ទៀត ដោយឈ្មោះ ណុច សុផាត បានធ្វើការរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] **ណារី** រហូតបានសម្រេចចំនួន ០១ដង ហើយលុះដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ទើបសមត្ថកិច្ចធ្វើការស្រាវជ្រាវរហូតឈានដល់ការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុផាត បាននៅខេត្តព្រះសីហនុ បញ្ជូនចាត់ការនៅអធិការដ្ឋាននគរបាលស្រុកពញាឮ ចាត់ការបន្តតាមនីតិវិធី ។

- **បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រ.ឍ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១. ឱ្យឈ្មោះ [redacted] សុផាត ភេទប្រុស អាយុ ២៤ឆ្នាំ រួចខ្លួនពីបទ នាំយកចេញអនីតិជនជាអាទ៍ដោយមិនស្របច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២០, ២៣ ខែមេសា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា០៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។



Scanned with CamScanner

២. ផ្តន្ទាទោសឈ្មោះ [redacted] សុផាត ភេទប្រុស អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ អនុវត្តទោសក្នុងពន្ធនាគារចំនួន ០៣ (បី)ឆ្នាំ ហើយទោសនៅសល់ព្យួរធម្មតា ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២០, ២៣ ខែមេសា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៣. បង្គាប់ឱ្យជនជាប់ចោទសងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមនីតិវិធីច្បាប់។

- **បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ០៧៧ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រ.ធរ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាលត្រង់ចំណុចទី១ និងទី២ នៃសេចក្តីសម្រេច ។

- **បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ៤៥ "ក្រVI.គ.ធ" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១. ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ០៧៧ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រ.ធរ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។

៣. បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] សុផាត តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ, ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ, ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី, ចំពោះមុខមេធាវីតំណាងដោយអាណត្តិ និងប្រកាសជាអសាធារណៈ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ។

បើកសិទ្ធិប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។



Scanned with CamScanner

- **បានឃើញ** បណ្ដឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ក្នុងការប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៥ “ក្រVI.គ.ធ” ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានឡើងធ្វើសេចក្ដីរាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ការសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញដូចខាងលើពុំត្រឹមត្រូវតាមគតិច្បាប់ទេ ព្រោះថា សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រ.ធរ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្ដាលទុកជាបានការដដែល ដោយយល់ឃើញថា តាមសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រ.ធរ/២១ ចុះថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្ដាល (សំអាងហេតុចំណុច៥) ដោយពុំបានលើកយកមាត្រានៃច្បាប់ ណាមួយមកសំអាងទេ។ សាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា (ចំណុច៧ វាក្យខណ្ឌ២ ការយល់ឃើញក្នុងសាលដីកា) *“ជនជាប់ចោទនិងជនរងគ្រោះបានស្រឡាញ់គ្នា ហើយការរួមភេទនោះកើតឡើងដោយស្ម័គ្រចិត្ត ប៉ុន្តែគ្រាន់តែជនរងគ្រោះទើបតែអាយុ ១២ ឆ្នាំប៉ុណ្ណោះ។ ដូចនេះតុលាការគប្បីពិចារណាសម្រេចអំពីការព្យួរទោស។”* សំអាងហេតុនេះគឺជាមូលដ្ឋានសម្រាប់ឱ្យសាលាឧទ្ធរណ៍សម្រេចអនុវត្តព្យួរទោសដែលផ្ទុយនឹងស្មារតីនៃមាត្រា ៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទ មាត្រានេះផ្ដន្ទាទោសជនណា (បុរស ឬ ស្ត្រី) ដែលរួមភេទជាមួយអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បានយល់ព្រមយ៉ាងពេញលេញក្នុងការរួមភេទបែបនេះ ឬមិនបានតទល់ក្នុងវិធីណាមួយក៏ដោយ។ ដោយសារតែច្បាប់នេះមិនបានផ្ដល់ឱ្យអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទ ក្នុងន័យច្បាប់ការព្រមព្រៀងបែបណាមួយក៏ដោយមិនមែនជា “ការយល់ព្រម” ទេ ហើយមាត្រានេះក៏ពុំមានចែងអំពីស្ថានសម្រាលទោសដែរ។ សូមតុលាការសម្រេចបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៤៥ “ក្រVI.គ.ធ” ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មី។ សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតាមច្បាប់។

+លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផាត បានធ្វើសេចក្ដីសន្និដ្ឋានការពារថា បណ្ដឹងសាទុក្ខរបស់មហាអយ្យការអមតុលាការកំពូល ធ្វើឡើងក្នុងពេលវេលាសមស្រប និងមានដាក់សារណារួចហើយ ដែលតុលាការកំពូលអាចពិចារណាបណ្ដឹងសាទុក្ខនេះបាន។ សាលដីកាសាលាឧទ្ធរណ៍បានពិចារណាត្រឹមត្រូវហើយ មាត្រា៤២ ចែងទោសអប្បបរមាចំនួន៥ឆ្នាំ។ សាលាដំបូង និងសាលាឧទ្ធរណ៍បានសម្រេច៥ឆ្នាំ ត្រឹមកម្រិតអប្បបរមា និងមិនបានផ្ដល់ការសម្រាលទោសទេ។ ខ្លឹមសារនៃបទប្បញ្ញត្តិច្បាប់ដែលដកស្រង់ខាងលើមិនហាមតុលាការប្រកាសទោសព្យួរឡើយ។ សាលាដំបូងអាចពិចារណា និងសម្រេច



Scanned with CamScanner

ទោសព្យួរបានដោយមិនពាក់ព័ន្ធនឹងអាយុរបស់ជនរងគ្រោះ។ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ក៏មិនបានហាមអនុវត្តទោសព្យួរផងដែរ។ តាមក្រមព្រហ្មទណ្ឌមាត្រា ១០៧ ចែងអំពីទោសព្យួរធម្មតាអាចអនុវត្តបានឱ្យតែចូលក្នុងលក្ខខណ្ឌនៃមាត្រានេះ។ ជនជាប់ចោទបានប្រព្រឹត្តបទល្មើសនេះជាលើកទីមួយ ដោយមិនបានបង្ខំ និងទទួលទោស៥ឆ្នាំ ដែលគាត់អាចទទួលទោសព្យួរបាន។

**សំណូមពរ** សូមតុលាការសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល។

+ជនជាប់ចោទឈ្មោះ [redacted] សុផាត បានឆ្លើយថា ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យខ្លួនទាំងស្រុង។

+លោក [redacted] សុភី ជាមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ចំពោះសវនាការនៅសាលាឧទ្ធរណ៍មានការជជែកវែកញែកគ្នាច្រើន ដោយសារតែការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាមិនមានការយល់ព្រមពីព្រះរាជអាជ្ញាធំទេ ហើយសាលាឧទ្ធរណ៍បានតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។ ជនជាប់ចោទមានគំនិតទុច្ចរិតបានលួងលោមកូនក្ដីខ្លួនយកទៅពេលនោះគាត់មានអាយុទើបតែជាង ១១ឆ្នាំតែប៉ុណ្ណោះ ដោយគ្មានការយល់ព្រមពីឪពុកម្ដាយឡើយហើយក៏មិនដែលស្គាល់ជនជាប់ចោទដែរ។ ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល។

**សំណូមពរ** សូមតុលាការបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និងបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីសម្រេចជាថ្មី។

- ក្រោយពីបានស្ដាប់សេចក្ដីរាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល
- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានពិនិត្យ ពិភាក្សា ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

**១-យល់ឃើញថា** បណ្ដឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការនិងមាត្រា ៤១៧ , មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២-យល់ឃើញថា** ការដែលតំណាងមហាអយ្យការបានលើកឡើងក្នុងសារណាការពារ ក៏ដូចជាសេចក្ដីសន្និដ្ឋាននាពេលសវនាការនៅចំពោះមុខតុលាការកំពូលថា ការសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញដូចខាងលើ



Scanned with CamScanner

ពុំត្រឹមត្រូវតាមគតិច្បាប់ទេ ព្រោះថា៖ សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រធរ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាលទុកជាបានការដដែល ដោយយល់ឃើញថា តាមសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ ០៣៥ ស.ព្រ.ធរ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល (សំអាងហេតុចំណុច៥) ដោយពុំបានលើកយកមាត្រានៃច្បាប់ណាមួយមកសំអាងទេ។ សាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា (ចំណុច៧ វាក្យខណ្ឌ២ ការយល់ឃើញក្នុងសាលដីកា) *“ជនជាប់ចោទនិងជនរងគ្រោះបានស្រឡាញ់គ្នា ហើយការរួមភេទនោះកើតឡើងដោយស្ម័គ្រចិត្ត ប៉ុន្តែគ្រាន់តែជនរងគ្រោះទើបតែអាយុ ១២ ឆ្នាំប៉ុណ្ណោះ។ ដូចនេះតុលាការគប្បីពិចារណាសម្រេចអំពីការព្យួរទោស។”* សំអាងហេតុនេះគឺជាមូលដ្ឋានសម្រាប់ឱ្យសាលាឧទ្ធរណ៍សម្រេចអនុវត្តព្យួរទោស ដែលផ្ទុយនឹងស្មារតីនៃមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទ មាត្រានេះផ្តន្ទាទោសជនណា (បុរស ឬ ស្ត្រី) ដែលរួមភេទជាមួយអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បានយល់ព្រមយ៉ាងពេញលេញក្នុងការរួមភេទបែបនេះ ឬ មិនបានតទល់ក្នុងវិធីណាមួយក៏ដោយ។ ដោយសារតែច្បាប់នេះមិនបានផ្តល់ឱ្យអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទ ក្នុងន័យច្បាប់ការព្រមព្រៀងបែបណាមួយក៏ដោយមិនមែនជា “ការយល់ព្រម” ទេ ហើយមាត្រានេះក៏ពុំមានចែងអំពីស្ថានសម្រាលទោសដែរ នោះតុលាការកំពូលពិនិត្យពិចារណាឃើញថា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពុំមានបទប្បញ្ញត្តិណាដែលហាមមិនឱ្យអនុវត្តការព្យួរទោសតាមក្រមព្រហ្មទណ្ឌនោះទេ។ ដូច្នេះការដែលតុលាការអង្គសេចក្តីសម្រេចព្យួរទោសជនជាប់ចោទ គឺមិនផ្ទុយនឹងច្បាប់ឡើយ ប៉ុន្តែតុលាការអង្គសេចក្តីមិនបានបង្ហាញអំពីបញ្ញត្តិច្បាប់ទាក់ទងនឹងការព្យួរទោសនៅក្នុងសេចក្តីសម្រេចស្របតាមមាត្រា ៣៥៧ (ការសរសេរសាលក្រមផ្នែកសំអាងហេតុនិងផ្នែកសម្រេច) នៃក្រមនីតិវិធីព្រហ្មទណ្ឌកថាខណ្ឌទី៣ ចែងថា “ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេសអំពីបទល្មើស ដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោស...។” ដោយហេតុថា ការដែលតុលាការអង្គសេចក្តីមិនបានចុះនិទ្ទេសអំពីអត្ថបទច្បាប់ទាក់ទងនឹងការព្យួរទោសនេះ គឺជាកំហុសផ្នែកសម្ភារៈដែលអាចជួសជុលបាន ដូច្នេះតុលាការកំពូលមិនចាំបាច់ប្រកាសបដិសេធសាលដីកាសាលាឧទ្ធរណ៍នោះទេ ប៉ុន្តែតុលាការកំពូលគប្បីចុះនិទ្ទេសអំពីបញ្ញត្តិច្បាប់មាត្រា ១០៧ (ទោសអាចនាំឱ្យមានការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ទៅក្នុងសេចក្តីសម្រេចត្រង់ចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តកណ្តាល ដើម្បីឱ្យសំណុំរឿងនេះមានភាពឆាប់រហ័ស។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៥ “ក្រVI.គ.ធ” ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ លើកលែងតែការភ្លេចបញ្ចូលនិទ្ទេសដូចការយល់ឃើញក្នុងសំអាងហេតុត្រង់ចំណុចទី២ ខាងលើ។

៤-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល ពុំមានមូលហេតុនៃបណ្តឹងសាទុក្ខស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រម នីតិវិធីព្រហ្មទណ្ឌទេ។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១. បដិសេធបណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញា នៃ មហាអយ្យការអមតុលាការកំពូល។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៥ "ក្រvi.គ.ឆ" ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដោយបញ្ចូលនិទ្ទេសត្រង់សេចក្តីសម្រេចចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌ លេខ ០៣៥ ស.ព្រ.ឃរ/២១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល បន្ថែមថា "និង តាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។"

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ និងប្រកាសនាសវនាការជា សាធារណៈនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ។

ឯកឧត្តម [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

លោកស្រី [redacted] ជាក្រឡាបញ្ជី

---

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។

ថ្ងៃសុក្រ ៧កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ៧កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner